ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤៧...សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការចាត់តាំងសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងជាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញសេចក្ដីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

## <u>សំរេច</u>

<u>ប្រការ ១</u> : បង្កើតអនុគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ដែលមានសមាសភាពដូចខាងក្រោម :

ក. <u>អនុគណៈកម្មការបរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាងហេដ្ឋារចនា</u>

<u>សម្ព័ន្ធ</u> :

| | | | |
|---|---|---|---|
| ១- | ឯកឧត្ដម គាត ឈន់ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- | ឯកឧត្ដម សុខ ចិន្ដា | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣- | ឯកឧត្ដម ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៤- | ឯកឧត្ដម អ៊ិត ប្រាំង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- | ឯកឧត្ដម សុភ ស៊ីផាន់ណា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- | ឯកឧត្ដម ឡា ណារ៉ាត | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៧- | ឯកឧត្ដម នុត ណារ៉ាង | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨- | ឯកឧត្ដម ចំន្ទ តុងអ៊ីវ | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | លោក ចាន់ សុធី | ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | លេខាធិការ |

ខ. <u>អនុគណៈកម្មការកិច្ចសំរួលពាណិជ្ជកម្ម</u> :

| | | | |
|---|---|---|---|
| ១- | ឯកឧត្ដម ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- | ឯកឧត្ដម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្ដម ញ៉ុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤- | ឯកឧត្ដម ខួត រ៉ាន់ឌី | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- | ឯកឧត្ដម តេង ឡៅ | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦- | ឯកឧត្ដម អ៊ុង គឹរុន | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៧- | ឯកឧត្ដម ជុំ អឿក | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨- | ឯកឧត្ដម ម៉ែន ស៊ីម៉ន | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៩- | ឯកឧត្ដម វ៉ា ថាង | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | លេខាធិការ |

គ_ **អនុគណៈកម្មការសហគ្រាសធុនតូច_មធ្យម** :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ប្រធាន |
| ២- | ឯកឧត្តម **ទ័ី ឆាយលាង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- | ឯកឧត្តម **យឹម ទឿនថន** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤- | ឯកឧត្តម **អ៊ូ ប៊ុនឡុង** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- | ឯកឧត្តម **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៦- | លោកជំទាវ **អ៊ឹម ស៊ីថៃ** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ៧- | ឯកឧត្តម **សួន សិទ្ធី** | អគ្គលេខាធិការរង ក.អ.ក | សមាជិក |
| ៨- | លោក **ណាង សុធី** | អគ្គនាយក សភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ៩- | លោក **កែវ រតនៈ** | ប្រធាននាយកដ្ឋានឧស្សាហកម្មតូច-សិប្បកម្ម | លេខាធិការ |

<u>ប្រការ ២</u> : អនុគណៈកម្មការនីមួយៗ មានភារកិច្ចរួម និងភារកិច្ចដោយឡែក ដូចខាងក្រោម :

ក_ **ភារកិច្ចរួម** :

- លើកឡើងនូវវិធានការចាំបាច់ ក្នុងក្របខ័ណ្ឌទទួលខុសត្រូវរបស់ខ្លួន ដើម្បីជំរុញការអនុវត្តន៍កម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ពិសេសលើរាល់ចំណុចពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ផ្នែកឯកជន ។
- ពង្រឹងការអនុវត្តន៍គោលការណ៍ "**អភិបាលកិច្ចល្អ**" នៅតាមគ្រប់ផ្នែកដែលពាក់ព័ន្ធ ដល់ការងារធុរកិច្ច និងការងារវិនិយោគឯកជន
- ពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយដៃគូអភិវឌ្ឍន៍ ទាំងអ្នកផ្តល់ជំនួយ ទាំងវិនិយោគិន ទាំងធុរជន ដើម្បីលើកឡើងនូវផែនការសកម្មភាពតាមផ្នែកនីមួយៗ និងស្វែងរកប្រភពហិរញ្ញប្បទាន សំរាប់ជំរុញផែនការសកម្មភាពទាំងនោះ អោយមានដំណើរការជាក់ស្តែង និងមានប្រសិទ្ធភាព
- សហការពិភាក្សា ដើម្បីកំណត់គោលនយោបាយ និងលើកឡើងជាវិធានការដោះស្រាយ ក្នុងក្របខ័ណ្ឌអនុគណៈកម្មការទាំង៣ សំរាប់រាល់ករណីដែលមិនស្ថិតក្នុងការទទួលខុសត្រូវរបស់អនុគណៈកម្មការនីមួយៗ
- មានសិទ្ធិធ្វើការងារប្រទាក់ក្រឡាគ្នា ជាមួយក្រុមការងារតាមវិស័យ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ដែលមានការពាក់ព័ន្ធ ។

ខ_ **ភារកិច្ចដោយឡែក** :

ខ១- <u>សំរាប់អនុគណៈកម្មការបរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ</u>

- លើកឡើងនូវវិធានការចាំបាច់ បំរើអោយការពង្រឹងនិងកែលំអបរិស្ថានវិនិយោគ និងធុរកិច្ច

- លើកគោលនយោបាយលើកទឹកចិត្ត ព្រាង ឬ/និងពិនិត្យសេចក្តីព្រាងរាល់លិខិតបទដ្ឋាន សំរាប់ណែនាំ និងជំរុញការចូលរួមរបស់ផ្នែកឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ
- រៀបចំបញ្ជីគំរោងហេដ្ឋារចនាសម្ព័ន្ធ គ្រប់ប្រភេទ ដែលទាមទារការចូលរួមពីសំណាក់ផ្នែកឯកជន

១២- <u>សំរាប់អនុគណៈកម្មការកិច្ចសំរួលពាណិជ្ជកម្ម</u>

- បន្ថយរាល់បែបបទស្មុគ្រស្មាញ និងវែងអន្លាយនៅតាមបណ្តាក្រសួង-ស្ថាប័ន ពាក់ព័ន្ធដល់ការនាំចូល-នាំចេញរបស់ក្រុមហ៊ុន
- បំបាត់ចោលនូវភារកិច្ចជាន់គ្នា របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញដំណើរការត្រួតពិនិត្យតែមួយកន្លែង អោយមានប្រសិទ្ធភាព
- ពង្រឹងការអនុវត្តន៍យន្តការ "**ច្រកចេញ-ចូលតែមួយ**" នៅតាមបណ្តាច្រកអន្តរជាតិ
- លើកឡើងនូវវិធានការចាំបាច់ បំរើអោយការអនុវត្តន៍ច្បាប់-បទបញ្ញត្តិនានា ចំពោះរាល់បាតុភាពអសកម្ម ប៉ះពាល់ដល់ការងារធុរកិច្ច

១៣- <u>សំរាប់អនុគណៈកម្មការសហគ្រាសធុនតូច-មធ្យម</u>

- លើកគោលនយោបាយលើកទឹកចិត្តចំពោះឧស្សាហកម្មផលិតទំនិញបំរើទីផ្សារក្នុងស្រុក ឬឧស្សាហកម្មផលិតទំនិញជំនួសការនាំចូល ដើម្បីឆ្លើយតបទៅនឹងសំណូមពរជាយុទ្ធសាស្ត្រ នៃការបង្កើតមូលដ្ឋានផលិតកម្មទំនិញក្នុងប្រទេសអោយបានច្រើន ពិសេសចំពោះមុខយុគសម័យនៃតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម
- កំណត់គោលនយោបាយលើកទឹកចិត្តនិងគាំទ្រសហគ្រាសធុនតូច-មធ្យម
- រៀបចំយុទ្ធសាស្ត្របង្កើនសមត្ថភាពប្រកួតប្រជែង សំរាប់សហគ្រាសធុនតូច-មធ្យម
- រៀបចំផែនការសកម្មភាព ជំរុញនិងគាំទ្រសហគ្រាសធុនតូច-មធ្យម ព្រមទាំងតាមដាន និងត្រួតពិនិត្យការអនុវត្តន៍
- ជំរុញការរៀបចំបទបញ្ញត្តិនានា ស្តីពីការគ្រប់គ្រងសហគ្រាសធុនតូច-មធ្យម
- អនុវត្តតួនាទីផ្សេងទៀត ដែលពាក់ព័ន្ធដល់ការជំរុញ និងគាំទ្រសហគ្រាសធុនតូច-មធ្យម ។

<u>ប្រការ ៣</u> : ប្រធានអនុគណៈកម្មការ អាចអញ្ជើញថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធមកចូលរួមការងារបាន ក្នុងករណីចាំបាច់ ។ ពេលប្រធានអវត្តមាន អនុគណៈកម្មការនីមួយៗ នឹងត្រូវដឹកនាំការងារ ឬប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬតំណាង តាមការប្រគល់សិទ្ធិរបស់ប្រធាន ។

សមាសភាពទាំងអស់នៃអនុគណៈកម្មការនីមួយៗ មានសិទ្ធិចាត់តាំងឬឯៗខ្លួននូវសមាជិកបំរុង០១រូប សំរាប់ជួយការងារ ឬជំនួស នៅពេលអវត្តមាន ។

**ប្រការ ៤ :** អនុគណៈកម្មការនីមួយៗ ត្រូវរាយការណ៍ជាប្រចាំ ជូនគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន អំពីរាល់សភាពការណ៍ ក៏ដូចជាវិធានការដែលបានដាក់ចេញ និងអំពីសំណូមពរដែលសុំការសំរេច ព្រមទាំងទិសដៅត្រូវអនុវត្តបន្ត។

**ប្រការ ៥ :** អនុគណៈកម្មការនីមួយៗ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួង ដែលប្រធានជាអ្នកទទួលខុសត្រូវ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ប្រធានសភាពាណិជ្ជកម្មកម្ពុជា អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនឹងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ៧ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន "ក.អ.ក"
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ